**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ៨០/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន នៅទីក្រុងគូឡាឡាំពួ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥

១. **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំពិសេសនៃរដ្ឋមន្ត្រីការបរទេសអាស៊ាន ស្តីអំពីបច្ចុប្បន្នភាពស្ថានការណ៍កម្ពុជា-ថៃ នៅទីក្រុងគូឡាឡាំពួ នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងតាមការឯកភាពរបស់នាយករដ្ឋមន្ត្រីម៉ាឡេស៊ី កម្ពុជា និងថៃ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥។ ក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ក៏បានចូលរួមធ្វើសេចក្តីរាយការណ៍ស្របតាមអាណត្តិរបស់ខ្លួនផងដែរ។

២. ក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះ **ឯកឧត្តម ប្រាក់ សុខុន** បានសម្តែងការសោកស្តាយដែលស្ថិរភាពដ៏ផុយស្រួយត្រូវបានបំផ្លាញដោយសារផ្ទុះការប្រយុទ្ធគ្នាឡើងវិញ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានជម្រាបជូនអង្គប្រជុំថា ក្នុងនាមជាប្រទេសមួយដែលផ្តល់តម្លៃខ្ពស់បំផុតដល់សន្តិភាព កម្ពុជាបានធ្វើគ្រប់បែបយ៉ាងអស់ពីលទ្ធភាព ដើម្បីឱ្យមានការអនុវត្តពេញលេញ និងការថែរក្សានូវបទឈប់បាញ់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ក៏ដូចជាសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៥ ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាចំពោះបទឈប់បាញ់ ព្រមទាំងវិធាននានាដើម្បីបន្ធូរបន្ថយភាពតានតឹង និងកសាងទំនុកចិត្ត ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍រួម។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានសម្តែងនូវសេចក្តីសង្ឃឹមថាភាគីទាំងពីរនឹងបន្តការប្តេជ្ញាចិត្តឡើងវិញ ដើម្បីអនុវត្តកិច្ចព្រមព្រៀងទាំងនេះឱ្យបានពេញលេញដោយស្មោះត្រង់ និងដោយសុទ្ធចិត្ត។

៣. **ឯកឧត្តម ប្រាក់ សុខុន** បញ្ជាក់ជាថ្មីឡើងវិញថា ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងពិតប្រាកដចំពោះបទឈប់បាញ់ដែលបានឯកភាពគ្នា កម្ពុជាបានអត់ធ្មត់ចៀសវាងមិនធ្វើការឆ្លើយតបអស់រយៈពេលជាង ២៤ ម៉ោង ក្រោយពីបានរងនូវការវាយប្រហារ នាថ្ងៃទី ៧ ខែធ្នូ ឆ្នាំ២០២៥។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំឭកអំពីការខកចិត្តចំពោះបរាជ័យ មិនអាចសម្រេចបាននូវបទឈប់បាញ់តាមការស្នើឡើងដោយឯកឧត្តមនាយករដ្ឋមន្ត្រី **ដាតូ សិរី អាន់វ៉ា អ៊ីប្រាហ៊ីម** នៅថ្ងៃទី៩ ទី១១ និងទី១៣ ខែធ្នូ ឆ្នាំ២០២៥ និងដោយឯកឧត្តមប្រធានាធិបតី **ដូណាល់ ត្រាំ** នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ដែលកម្ពុជាបានទទួលយកដោយមិនស្ទាក់ស្ទើរ ហើយមិនត្រឹមតែប៉ុណ្ណោះ ថែមទាំងបានអំពាវនាវស្នើឱ្យប្រទេស

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ម៉ាឡេស៊ី និងសហរដ្ឋអាមេរិកប្រើប្រាស់មធ្យោបាយ រួមទាំងសមត្ថភាពផ្កាយរណប ដើម្បីជួយត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នូវការអនុលោមតាមបទឈប់បាញ់។

៤. **ឯកឧត្តម ប្រាក់ សុខុន** បានសង្កត់ធ្ងន់ថា គោលបំណងចម្បងរបស់កម្ពុជា គឺការបញ្ចប់នូវទុក្ខវេទនារបស់ប្រជាជន ទប់ស្កាត់ការបំផ្លិចបំផ្លាញបន្ថែមទៀត និងបន្តដើរលើមាគ៌ាឆ្ពោះទៅរកសន្តិភាព ដំណោះស្រាយប្រកបដោយយុត្តិធម៌ និងចីរកាល។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានបញ្ជាក់ជាថ្មីអំពីសារៈសំខាន់នៃការរក្សាភាពជឿជាក់ទៅលើអាស៊ាន ក្នុងនាមជាអង្គការតំបន់មួយដែលសម្រេចបានជោគជ័យបំផុតលើពិភពលោក ដោយមានសមត្ថភាពអាចជួយរដ្ឋសមាជិករបស់ខ្លួន ដោះស្រាយជម្លោះដោយសន្តិវិធី និងស្របតាមច្បាប់អន្តរជាតិ រួមទាំងការបដិសេធចំពោះការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង។

៥. **ឯកឧត្តម ប្រាក់ សុខុន** បានគូសបញ្ជាក់អំពីវឌ្ឍនភាពដែលសម្រេចបានស្របតាមសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ជាពិសេសពាក់ព័ន្ធនឹងការដកអាវុធធុនធ្ងន់ចេញពីព្រំដែន ការដោះមីនមនុស្សធម៌ និងការងារខណ្ឌសីមាព្រំដែន ក្រោមក្របខណ្ឌគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែននៃប្រទេសទាំងពីរ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានស្នើសុំរដ្ឋសមាជិកអាស៊ានឯទៀត ធ្វើការជំរុញនិងគាំទ្រវិធានការដូចខាងក្រោម៖

- ការបញ្ឈប់ជាបន្ទាន់នូវអរិភាពទាំងអស់ដោយភាគីទាំងពីរ ចាប់ផ្តើមពីម៉ោង ២២:០០ ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងការគោរព និងអនុវត្តពេញលេញចំពោះកិច្ចព្រមព្រៀងឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ក៏ដូចជាកិច្ចព្រមព្រៀងផ្សេងទៀតដែលសម្រេចបានក្រោមក្របខណ្ឌនេះ។
- ការកែសម្រួលកងកម្លាំងប្រដាប់អាវុធនៃប្រទេសទាំងពីរទៅកាន់ទីតាំងដើម ដូចមុនពេលផ្ទុះឡើងនៃអរិភាព និងការវិលត្រឡប់ទៅកាន់ផ្ទះសម្បែង បន្តជីវភាពដូចមុនពេលផ្ទុះជម្លោះរបស់ប្រជាជនជនស៊ីវិលរស់នៅតំបន់ព្រំដែនដែលរងផលប៉ះពាល់ ប្រកបដោយសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងគ្មានការរារាំង។
- ការដោះស្រាយជម្លោះ រួមទាំងការកំណត់ខណ្ឌសីមាព្រំដែន តែតាមរយៈមធ្យោបាយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ព្រមទាំងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលមានស្រាប់រវាងកម្ពុជា និងថៃ រួមទាំងការបន្តអនុវត្តឡើងវិញជាបន្ទាន់នូវសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ។

៦. **ឯកឧត្តម ប្រាក់ សុខុន** បានបញ្ចប់សេចក្តីថ្លែងការណ៍ ដោយគូសបញ្ជាក់អំពីការចាំបាច់ផ្នែកមនុស្សធម៌ត្រូវមានការដោះលែងដោយគ្មានបង្អែបង្អង់ និងឥតលក្ខខណ្ឌនូវយោធិនកម្ពុជាទាំង ១៨ នាក់ ដែលកំពុងបន្តស្ថិតក្នុងការឃុំឃាំង។

៧. កិច្ចប្រជុំបានវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏សកម្ម និងការបន្តចូលរួមចំណែករបស់ប្រទេសម៉ាឡេស៊ី សហរដ្ឋអាមេរិក និងប្រទេសចិន ក្នុងការជំរុញដំណោះស្រាយដោយសន្តិវិធីសម្រាប់ចំពោះជម្លោះដែលកំពុងបន្តវិវត្តទៅមុខ ហើយក៏បានជំរុញឱ្យភាគីទាំងពីរវិលត្រឡប់ទៅរកការអនុវត្តតាមឱ្យពេញលេញ និងប្រកបដោយប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ល្អ

ផលនៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការព្រំដែនទូទៅ(GBC) នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ដែលបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២៥។

៨. កិច្ចប្រជុំបានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការកើនឡើងនៃចំនួនអ្នកស្លាប់ និងរបួស ការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និងប្រជាជនភៀសសឹកទាំងសងខាងព្រំដែន បណ្តាលមកពីជម្លោះកាន់តែធ្ងន់ធ្ងរ និងបានអំពាវនាវឱ្យប្រទេសទាំងពីរវិលត្រឡប់ទៅរកការសន្ទនា រួមទាំងតាមរយៈយន្តការទ្វេភាគី និងការសម្របសម្រួលរបស់ប្រធានអាស៊ាន។ កិច្ចប្រជុំបានសង្កត់ធ្ងន់ថា ជនស៊ីវិលដែលរស់នៅក្នុងតំបន់ព្រំដែនដែលរងផលប៉ះពាល់ គួរតែត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់ទៅផ្ទះសម្បែងវិញដោយសុវត្ថិភាព ហើយទីតាំងសាសនា និងបេតិកភណ្ឌវប្បធម៌ត្រូវតែទទួលបាននូវការការពារមិនឱ្យរងការវាយប្រហារដោយអាវុធឡើយ។

៩. ជាមួយនឹងការបញ្ជាក់អំពីសារៈសំខាន់នៃឯកភាព និងសាមគ្គីភាពអាស៊ាន ក៏ដូចជាមជ្ឈភាពអាស៊ានក្នុងការធានាសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពក្នុងតំបន់ កិច្ចប្រជុំបានជំរុញឱ្យភាគីទាំងពីរគោរពគោលការណ៍នៃច្បាប់អន្តរជាតិ សន្តិសហវិជ្ជមាន និងកិច្ចសហប្រតិបត្តិការពហុភាគី ក្នុងការស្វែងរកដំណោះស្រាយប្រកបដោយយុត្តិធម៌ និងចីរកាលចំពោះស្ថានការណ៍បច្ចុប្បន្ន។

១០. កិច្ចប្រជុំបានបញ្ចប់ដោយការចេញសេចក្តីប្រកាសរបស់ប្រធានអាស៊ាន ស្តីពីលទ្ធផលនៃកិច្ចពិភាក្សារបស់រដ្ឋមន្ត្រីទាំងអស់ ដែលកំណត់នូវបរិយាកាសសម្រាប់បន្តកិច្ចប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាបាននូវបទឈប់បាញ់ជាបន្ទាន់ និងគ្មានលក្ខខណ្ឌ ព្រមទាំងការប្តេជ្ញាចិត្តដោយស្មោះត្រង់ចំពោះមាគ៌ានៃការកាត់បន្ថយភាពតានតឹង ការកសាងទំនុកចិត្ត និងការស្វែងរកសន្តិភាពចីរកាល។

ថ្ងៃចន្ទ ៣កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥